០០២/១៩ កញ្ញា ២០០៧/អវតក/អជសង
E137/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 12 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសង
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន**
ចៅក្រម Claudia FENZ
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

## សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម SILVIA CARTWRIGHT

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Jacques VERGÈS

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងរបស់ នួន ជា ប្តឹងជំទាស់ចៅក្រម Silvia Cartwright និងសំណើរបស់ អៀង សារី ស្នើសុំឱ្យស៊ើបអង្កេតលើការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង*[១]។ អង្គជំនុំជម្រះសាលាដំបូង ដែលមានសមាសភាពចៅក្រមប្រធាន និល ណុន ចៅក្រម Claudia FENZ ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្តរា ចេញសេចក្តីសម្រេចដូចទៅ។

## ២. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី នួន ជា បានបញ្ជូនលិខិតមួយច្បាប់ជូនទៅប្រធានអង្គជំនុំជម្រះសាលាដំបូង ដោយបានរៀបរាប់ថា ក្រុមរបស់ខ្លួនបានទទួលព័ត៌មានពីប្រភពអនាមិកមួយដែលបញ្ជាក់ថា កិច្ចប្រជុំជាមួយ *តែភាគីម្ខាង* នៃរឿងក្តី បានកើតឡើងរវាងចៅក្រម Cartwright និងសហព្រះរាជអាជ្ញាអន្តរជាតិ[២]។ ក្រុមមេធាវីការពារក្តីបានអះអាងថា កិច្ចប្រជុំ ទាំងនេះមួយចំនួន ក៏មានការចូលរួមពីមន្ត្រីសម្របសម្រួលខាង UNAKRT និងអនុ-ប្រធានរដ្ឋបាលរបស់ អ.វ.ត.ក ផងដែរ។ ក្រុមមេធាវីការពារក្តីបានស្នើសុំការឆ្លើយបំភ្លឺពីចៅក្រម Cartwright នៅថ្ងៃទី ០១ និង ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក៏ប៉ុន្តែ ក្រុមរបស់ខ្លួនពុំទទួលបានការឆ្លើយតបមកវិញឡើយ[៣]។

៣. នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អនុប្រធានរដ្ឋបាលបានឆ្លើយតបទៅនឹងសំណើរបស់ អៀង សារី ដោយលើកឡើងថា៖

---

[១] បណ្តឹងជំទាស់ជាបន្ទាន់ចំពោះចៅក្រម Cartwright របស់ក្រុមមេធាវីការពារក្តី នួន ជា ឯកសារ E137/2 ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("បណ្តឹងរបស់ នួន ជា") និង សំណើរបស់លោក អៀង សារី ស្នើឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការ ប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត ឯកសារ E137/3 ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("សំណើរបស់ អៀង សារី")។

[២] សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Cartwright, Andrew Cayley និង/ឬ Knut Rosandhaug ឯកសារ E137 ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("សំណើសុំព័ត៌មានរបស់ នួន ជា")។

[៣] សំណើសុំព័ត៌មានរបស់ នួន ជា។

ការស្នើសុំឱ្យមានកិច្ចប្រជុំជាទៀងទាត់រវាងចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិ និងមន្ត្រីសម្របសម្រួលខាង UNAKRT ដោយជូនដំណឹងភាគីជាតិកម្ពុជាឱ្យបានដឹងជ្រួតជ្រាប គឺបានស្នើសុំឡើងដោយមន្ត្រីច្បាប់តំណាងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងអំឡុងពេលលោកស្រីបានមកធ្វើទស្សនកិច្ចនៅ អ.វ.ត.ក ក្នុងខែ មេសា ឆ្នាំ ២០១១។ សំណើសុំឱ្យមានកិច្ចប្រជុំនេះ មានគោលបំណងបន្ថែមការផ្តោតការយកចិត្តទុកដាក់លើការប្រាស្រ័យ ទាក់ទងគ្នារវាងភាគី អ.ស.ប ជាមួយភាគីជាតិកម្ពុជា ព្រមទាំងជាមួយនឹងទីស្នាក់ការកណ្តាលរបស់ អ.ស.ប។ កិច្ចប្រជុំទាំងនេះគឺជាការយកគំរូតាមគណៈកម្មាធិការសម្របសម្រួលក្នុងទម្រង់ក្រៅផ្លូវការ ដែលគណៈកម្មាធិការទាំងនេះ គឺជាបទដ្ឋាននៅក្នុងសាលាក្តីរបស់ អ.ស.ប និងសាលាក្តីដែលទទួលការជួយជ្រោមជ្រែងពី អ.ស.ប ហើយធ្វើឡើងក្នុងគោលបំណងផ្តោតលើបញ្ហារដ្ឋបាល និងការរៀបចំ ដោយទោះក្នុងទម្រង់ណាក៏ដោយ ពុំពិភាក្សាលើខ្លឹមសារនៃរឿងក្តីនៅចំពោះមុខ អ.វ.ត.ក ឡើយ[៤]។

៤. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់សំណើសុំមួយបន្ថែមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំព័ត៌មានថាតើនៅក្នុងកិច្ចប្រជុំទាំងនោះ មានបានពិភាក្សាលើការជ្រៀតជ្រែកផ្នែកនយោបាយដែលបានចោទប្រកាន់ ឬ មានការពិភាក្សាលើសំណើរបស់ នួន ជា ស្នើសុំឱ្យស៊ើបអង្កេតដែរ ឬទេ[៥]។ ទោះបីជាបានអះអាងថា ក្រុមមេធាវីការពារក្តីមានហេតុផលជឿជាក់ថា បញ្ហាទាំងនេះបានយកមកពិភាក្សាក៏ដោយ ក៏ពុំមានព័ត៌មាន ឬការរៀបរាប់លម្អិតណាមួយបានផ្តល់ជូន ដើម្បីជាមូលដ្ឋានគាំទ្រដល់ការអះអាងនេះឡើយ[៦]។

## ៣. <u>សារណា</u>

### ៣.១. <u>បណ្តឹងរបស់ក្រុមមេធាវីការពារក្តី</u>

៥. នួន ជា បានសន្និដ្ឋានថា ការចូលរួមរបស់ចៅក្រម Cartwright នៅក្នុងកិច្ចប្រជុំរវាង*តែភាគីម្ខាង* ជាមួយនឹងសហព្រះរាជអាជ្ញា និងអនុប្រធានការិយាល័យរដ្ឋបាល នៃ អ.វ.ត.ក បាននាំឱ្យមាន

---

[៤] អ៊ីម៉ែលទាក់ទងរវាងអនុប្រធានការិយាល័យរដ្ឋបាល និងក្រុមមេធាវីការពារក្តី ឯកសារ E137/1។

[៥] សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Silvia Cartwright, សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានរដ្ឋបាល ឯកសារ E137/1 ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("សំណើសុំព័ត៌មានរបស់ នួន ជា លើកទីពីរ") កថាខណ្ឌ ៧។

[៦] សំណើសុំព័ត៌មានរបស់ នួន ជា លើកទីពីរ កថាខណ្ឌ ៧។

ការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន[៧]។ អៀង សារី បានសន្និដ្ឋានដោយផ្អែកលើកិច្ចប្រជុំទាំងនេះថា ទោះក្នុងកាលៈទេសៈណាក៏ដោយ ចៅក្រម Cartwright អាចទំនងជាមិនបំពេញកិច្ចដោយឯករាជ្យលើសំណុំរឿង ០០២ ហើយចៅក្រមរូបនេះអាចមានភាពលម្អៀងទៅខាងការិយាល័យសហព្រះរាជអាជ្ញា[៨]។ នួន ជា និង អៀង សារី បានសន្និដ្ឋានបន្ថែមទៀតថា ដោយហេតុថា គណៈកម្មាធិការរដ្ឋបាលតុលាការ គឺជាយន្តការផ្តាច់មុខសម្រាប់ចាត់ចែងលើការជួយជ្រោមជ្រែងដល់តុលាការ និងផ្នែករដ្ឋបាល ហេតុដូច្នេះ វាពុំមានមូលដ្ឋានផ្លូវច្បាប់បើកឲ្យមានកិច្ចប្រជុំជាមួយ*តែភាគីម្ខាង*ក្នុងលក្ខណៈក្រៅផ្លូវការ និង*ក្នុងលក្ខណៈពិសេស* ដូច្នេះឡើយ[៩]។

៦. បើទោះជាក្រមសីលធម៌ចៅក្រម អ.វ.ត.ក ពុំបានហាមឃាត់ជាក់លាក់ក៏ដោយ ក៏ អៀង សារី និង នួន ជា បានលើកឡើងថា ការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* ត្រូវបានហាមឃាត់នៅក្នុងក្រមសីលធម៌ចៅក្រមកម្ពុជា និងបទដ្ឋានអន្តរជាតិ[១០]។ អៀង សារី បានលើកឡើងថា ការស៊ើបអង្កេតមួយចាំបាច់ត្រូវធ្វើឡើងដើម្បីកំណត់ ថាតើវាអាចបណ្តាលឲ្យកើតមាននូវការយល់ដឹងដោយសុភវិនិច្ឆ័យអំពីភាពលម្អៀង ផ្អែកតាមកិច្ចប្រជុំទាំងនេះដែរ ឬទេ។ អៀង សារី បានផ្តល់ទឡ្ហីករណ៍ថា កិច្ចប្រជុំទាំងនេះបានប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ពីព្រោះតែ "វាមិនពិបាកយល់ទេថាចៅក្រមមួយរូប ដែលបានបើកផ្លូវឲ្យព្រះរាជអាជ្ញាមួយរូប មានទំនាក់ទំនង*សម្ងាត់* ច្រើនលើកច្រើនសាជាមួយគាត់នោះ នឹងធ្វើការជំនុំជម្រះលម្អៀងទៅខាងភាគីនោះ ទោះជាមិនដោយចេតនាក៏ដោយ"[១១]។

---

[៧] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ១៥។

[៨] សំណើរបស់ អៀង សារី កថាខណ្ឌ ២៦, ៣១-៣២។

[៩] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ១១, ១៦។ សំណើរបស់ អៀង សារី កថាខណ្ឌ ២៥។

[១០] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ១០។ សំណើរបស់ អៀង សារី កថាខណ្ឌ ១៣, ១៦, ២០, ២១ និង ២៨ ( ដោយបានចោទប្រកាន់បន្ថែមទៀតថា កិច្ចប្រជុំទាំងនេះនឹងត្រូវបានហាមឃាត់ ដោយគោលការណ៍ណែនាំរបស់ប្រទេសនូវែលសេឡង់ ស្តីពីក្រមសីលធម៌ចៅក្រម និងក្រមសីលធម៌គណៈមេធាវីរបស់ប្រទេសអង់គ្លេស និងប្រទេសវ៉ែល។

[១១] សំណើរបស់ អៀង សារី កថាខណ្ឌ ២៥, ២៩, និង ៣៣ ("វាជាការតវ៉ាហួសហេតុថា ទាំងលោក Cayley និងចៅក្រម Silvia Cartwright បានដឹងអំពីបញ្ហាទាំងនេះ ដែលគេអាចតវ៉ាដោយលើកឡើងថា វាបានបណ្តាលឲ្យកើតមាននូវការយល់ដឹងដោយសុភវិនិច្ឆ័យអំពីភាពលម្អៀង)។

៧. នួន ជា និង អៀង សារី បានអះអាងថា ទង្វើរបស់ចៅក្រម Cartwright នឹងធ្វើឱ្យអ្នកសង្កេតការណ៍ដោយមិនលម្អៀង និងដោយសុភវិនិច្ឆ័យ មានការសង្ស័យលើលទ្ធភាពរបស់ចៅក្រមរូបនេះក្នុងការបំពេញភារកិច្ចជាចៅក្រមដោយឯករាជ្យ និងមិនលម្អៀង ដោយសារពួកគេពុំមានកំណត់ហេតុនៃកិច្ចប្រជុំ និងដោយសារចៅក្រម Cartwright ខកខានពុំបានលាតត្រដាងព័ត៌មានពាក់ព័ន្ធនឹងកិច្ចប្រជុំទាំងនោះ[១២]។

៨. អៀង សារី បានស្នើសុំអង្គជំនុំជម្រះសាលាដំបូង ឱ្យកោះហៅសហព្រះរាជអាជ្ញាអន្តរជាតិ និង "ជំរុញ" ឱ្យចៅក្រម Cartwright ចេញសេចក្តីប្រកាសលាតត្រដាងព័ត៌មានអំពីកិច្ចប្រជុំទាំងនោះ[១៣]។ អៀង សារី ក៏បានស្នើសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈមួយដើម្បីសម្រេចលើសំណើរបស់ខ្លួន ឬ បើមិនដូច្នោះទេ ស្នើសុំការអនុញ្ញាតឱ្យខ្លួនមានសិទ្ធិដាក់ការឆ្លើយតបទៅនឹងចម្លើយតប[១៤]។ នួន ជា បានធ្វើបណ្តឹងជំទាស់ចិត្តលើចៅក្រម Cartwright និងស្នើឱ្យដកលោកស្រីចៅក្រមចេញពីសំណុំរឿង ០០២ ជាបន្ទាន់[១៥]។

## <u>៣.២. ចម្លើយតបរបស់សហព្រះរាជអាជ្ញា</u>

៩. សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា បណ្តឹងជំទាស់ចិត្តរបស់ នួន ជា ពុំអាចទទួលយកបានឡើយ ពីព្រោះបណ្តឹងនេះ ខកខានពុំបានផ្អែកលើភស្តុតាងគាំទ្រលើមូលដ្ឋាននៃការចោទប្រកាន់ចំពោះបណ្តឹងជំទាស់ចិត្ត។ មូលដ្ឋានគាំទ្រតែមួយគត់ចំពោះការអះអាងថា កិច្ចប្រជុំក្រៅផ្លូវការទាំងនេះ ពុំសមស្រប គឺការសរសេរយោងនៅក្នុងជើងទំព័រលើព័ត៌មានដែលក្រុមមេធាវីការពារក្តីបានលើកឡើងថា បានទទួលមកពី "ប្រភពគួរឱ្យទុកចិត្តមួយ" ដែល "បច្ចុប្បន្នមានបំណងនៅតែសុំមិនបញ្ចេញឈ្មោះ"[១៦]។ ការខកខានពុំបានកំណត់អត្តសញ្ញាណអំពីប្រភពនេះ ឬ ពុំបានផ្តល់សេចក្តី

---

[១២] បណ្តឹងរបស់ នួន ជា កថាខណ្ឌ ២ ១៥-១៩ (ដោយកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានទទួល "សំណើសុំរបស់ នួន ជា ស្នើសុំការស៊ើបអង្កេតលើការចោទប្រកាន់ អំពីការជ្រៀតជ្រែកនយោបាយដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំទាំងនេះ)។ សំណើរបស់ អៀង សារី កថាខណ្ឌ ២៤-២៦, ៣០-៣២។

[១៣] សំណើរបស់ អៀង សារី ទំព័រ ១៥។

[១៤] សំណើរបស់ អៀង សារី កថាខណ្ឌ ១៥។

[១៥] បណ្តឹងរបស់ នួន ជា ទំព័រ ៩។

[១៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹង៖ 1) បណ្តឹងជំទាស់ចិត្តរបស់ នួន ជា ជាបន្ទាន់ចំពោះចៅក្រម Cartwright និង 2) សំណើរបស់ អៀង សារី សុំឱ្យមានកិច្ចស៊ើបសួរ ទាក់ទងនឹងការទំនាក់ទំនងភាគីតែម្ខាង E137/4, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ៩-១០។

រៀបរាប់ជាលាយលក្ខណ៍អក្សរពីប្រភពនេះ (ទោះបីក្នុងទម្រង់កោសលុប ឬ ទម្រង់សម្ងាត់បំផុតក៏ដោយ) ក៏ភាគីដាក់បណ្តឹងពុំអាចរួចបន្ទុក ក្នុងការផ្តល់ភស្តុតាងដើម្បីជាមូលដ្ឋានគាំទ្រលើបណ្តឹងជំទាស់ចិត្តរបស់ខ្លួនឡើយ[១៧] ហើយការតវ៉ាថា ចៅក្រម Cartwright ពុំបានឆ្លើយតបទៅនឹងការដាក់សំណើមុនៗរបស់ នួន ជា លើបញ្ហានេះ ក៏ពុំបានបំពេញលក្ខខណ្ឌអប្បបរមាផងដែរ ដោយសារតែ "ប្រសិនបើលក្ខខណ្ឌត្រឹមប៉ុណ្ណេះគ្រប់គ្រាន់នោះ នោះចៅក្រមដែលមិនឆ្លើយតបទៅនឹងការដាក់ឯកសារដែលឥតបានការ អាចជាកម្មវត្ថុនៃបណ្តឹងជំទាស់ចិត្តទាំងអស់"[១៨]។

១០. សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ចៅក្រម Cartwright គឺជាចៅក្រមមានគុណវុឌ្ឍិ និងបទពិសោធន៍ខ្ពស់ ហើយ "អ្នកសង្កេតការណ៍ដោយសុភវិនិច្ឆ័យនឹងមិនជាទំនងសន្មតថា លោកស្រីចៅក្រមពាក់ព័ន្ធនឹងទង្វើមិនសមរម្យ ដែលជាការរំលោភបំពានលើក្រមសីលធម៌ជាចៅក្រម និងផ្ទុយពីកាតព្វកិច្ចវិជ្ជាជីវៈរបស់លោកស្រីឡើយ"[១៩]។ ការប្រាស្រ័យទាក់ទងរវាង អនុប្រធានកិច្ចប្រជុំពេញអង្គ សហព្រះរាជអាជ្ញា និង/ឬ អនុប្រធានការិយាល័យរដ្ឋបាលនោះ មានលក្ខណៈចាំបាច់ និង សមស្រប នៅក្នុងបរិបទនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតូបនីយកម្ម ដូចជា អ.វ.ត.ក ដែលសហព្រះរាជអាជ្ញាអន្តរជាតិ មិនមានតួនាទីត្រឹមតែជាតួនាទីក្នុងនាមជាភាគីនៃកិច្ចដំណើរការនីតិវិធីឡើយ[២០]។ ទម្លាប់អនុវត្តដ៏ប្រពៃនៃតុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតូបនីយកម្ម និងអន្តរជាតិនានា បង្ហាញឱ្យឃើញនូវតម្រូវការនៃយន្តការជួយជ្រោមជ្រែង ផ្នែករដ្ឋបាលឱ្យមានប្រសិទ្ធភាព ការគ្រប់គ្រងលើធនធានដោយសន្សំសំចៃ និងការសម្របសម្រួលយុទ្ធសាស្ត្រក្នុងកម្រិតខ្ពស់រវាងការិយាល័យរដ្ឋបាល ការិយាល័យសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះ[២១]។

១១. ពាក់ព័ន្ធនឹងសំណើរបស់ អៀង សារី សហព្រះរាជអាជ្ញាលើកឡើងថា ដើម្បីបំពេញទៅតាមបន្ទុករបស់ខ្លួន ដូចមានចែងក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ក្រុមមេធាវីរបស់ អៀង សារី ត្រូវតែបង្ហាញ

---

[១៧] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៩-១០។

[១៨] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១០។

[១៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៦-១៧, ២៤ (ដោយកត់សម្គាល់ឃើញថា អ្នកសង្កេតការណ៍ដោយសុភវិនិច្ឆ័យនឹងដឹងថា នៅក្នុងសាលាក្តីអន្តរជាតិ ចៅក្រមមានមុខងារផ្នែករដ្ឋបាល ដែលត្រូវឱ្យចៅក្រមទាំងនោះជួបប្រជុំជាមួយនឹងសមាជិករបស់ស្ថាប័នអយ្យការ ដោយសារហេតុនេះហើយ អ្នកសង្កេតការណ៍ទាំងនេះពុំសង្ស័យនឹងភាពមិនលម្អៀងរបស់ចៅក្រមឡើយ ហើយប្រព័ន្ធច្បាប់ស៊ីវិលបើកឱ្យចៅក្រម និងរដ្ឋអាជ្ញាទាក់ទងគ្នាបាន)។

[២០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២០-២១។

[២១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២១។

សំអាងហេតុ ដើម្បីឱ្យជឿជាក់បានថាបុគ្គលម្នាក់ "បានជ្រៀតជ្រែកកិច្ចការរដ្ឋបាលតុលាការដោយដឹងខ្លួនជាមុន និងដោយចេតនា" ដោយផ្អែកលើ "មូលដ្ឋានជាក់លាក់ ឬសំអាងហេតុដែលជាមូលហេតុនៃជំនឿរបស់ពួកគេ"[២២]។ ក្រុមមេធាវីរបស់ អៀង សារី មិនបានបង្ហាញមូលដ្ឋានជាក់លាក់ដើម្បីបញ្ជាក់ថា កិច្ចប្រជុំទាំងនេះនាំឱ្យមានការជ្រៀតជ្រែកដល់កិច្ចការរដ្ឋបាលតុលាការ ឬការជ្រៀតជ្រែកដូចដែលបានចោទប្រកាន់នេះត្រូវបានធ្វើឡើងក្នុងចេតនាចាំបាច់នោះទេ[២៣]។ ដូច្នេះ សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធពាក្យសុំរបស់ នួន ជា និងសំណើរបស់ អៀង សារី[២៤]។

## ៤. ច្បាប់ជាធរមាន

១២. ដោយសារតែញត្តិរបស់ អៀង សារី មានខ្លឹមសារជាបណ្តឹងជំទាស់ចៅក្រម អង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា បណ្តឹងនេះ បានផ្អែកលើវិធាន ៣៥ នៃវិធានផ្ទៃក្នុងដោយពុំត្រឹមត្រូវ ។ បញ្ញត្តិដែលពាក់ព័ន្ធគួរតែជាវិធាន ៣៤(២) នៃវិធានផ្ទៃក្នុងទើបត្រឹមត្រូវជាង។ វិធាន ៣៤(២) ចែងថា៖

> ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមានភាពលម្អៀង។

១៣. យុត្តិសាស្ត្ររបស់ អ.វ.ត.ក និងសាលាក្តីអន្តរជាតិដទៃទៀត លើកឡើងស៊ីសង្វាក់គ្នាថា លក្ខខណ្ឌនៃភាពអនាគតិត្រូវបានរំលោភបំពាននៅពេលណាចៅក្រមមួយរូបលម្អៀងពិតប្រាកដមែន ឬនៅពេលណាដែលមានការស្តែងឱ្យឃើញនូវភាពលម្អៀងដូច្នេះមែន[២៥]។ ការស្តែងឱ្យឃើញនូវភាពលម្អៀងអាចកើតមានឡើង ប្រសិនបើ៖

---

[២២] សារណាតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧។

[២៣] សារណាតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨-២៩។

[២៤] សារណាតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០។

[២៥] *សហព្រះរាជអាជ្ញា ទល់នឹង Furundžija* សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃសាលាក្តី ICTY (IT-95-17/1-A) ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ("សាលដីកាបណ្តឹងសាទុក្ខ *Furundžija*") កថាខណ្ឌ ១៨១-១៨៨។

ក) ចៅក្រមមួយរូបគឺជាភាគីក្នុងរឿងក្តី ឬមានផលប្រយោជន៍ហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ដែលកើតចេញពីលទ្ធផលនៃរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមរូបនោះនឹងឈានទៅរកការលើកស្ទួយបុព្វហេតុមួយ ដែលគាត់មានចំណែកក្នុងនោះ ឬ

ខ) កាលៈទេសៈមួយចំនួន អាចនាំឱ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណម្នាក់ ដែលទទួលបានព័ត៌មានសមស្រប ល្មមយល់បានថាមានភាពលម្អៀង[២៦]។

១៤. អ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណម្នាក់ ក្នុងន័យនេះគឺជា "ជនម្នាក់ដែលទទួលបានព័ត៌មានសមស្រប មានការដឹងឮរាល់គ្រប់កាលៈទេសៈដែលពាក់ព័ន្ធ រួមទាំងប្រពៃណីនៃសុចរិតភាព និងអនាគតិ ដែលបង្កើតបានជាផ្នែកមួយនៃសាវតារ និងបានយល់ដឹងអំពីការពិតដែលថា អនាគតិគឺជាករណីយកិច្ចមួយក្នុងចំណោមករណីយកិច្ចដទៃទៀត ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់ ដូចដែលពួកគាត់ បានធ្វើសច្ចាប្រណិធាន"[២៧]។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក បានគូសបញ្ជាក់ថា គេត្រូវចាប់ផ្តើមសម្រេចលើការចោទប្រកាន់អំពីភាពលម្អៀងណាមួយ ចាប់ពីចំណុចនៃការសន្មតជាមុនសិនថា គ្មានភាពលម្អៀងដែលមានចំពោះចៅក្រមនៅ អ.វ.ត.ក ដោយផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ការតែងតាំងពួកគាត់ជាចៅក្រមនោះ[២៨]។ ភាគីដែលប្តឹងជំទាស់ចៅក្រម មានបន្ទុកត្រូវបង្ហាញភ័ស្តុតាងឱ្យផ្ទុយពីការសន្មតទុកជាមុនបែបនេះ ដែលជាតម្រូវឱ្យភាគីដាក់បណ្តឹងត្រូវបំពេញ[២៩]។ អនុលោមតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង បណ្តឹងដូច្នេះ "ត្រូវតែបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ និងត្រូវផ្តល់ភ័ស្តុតាងគាំទ្រ"។ បណ្តឹងដែលមានភាពស្មានៗ ឬផ្អែកតែទៅលើ "ការយល់ឃើញ ឬការសង្ស័យ

---

[២៦] សាលដីកាបណ្តឹងសាទុក្ខ *Furundžija* កថាខណ្ឌ ១៨៩។

[២៧] សាលដីកាបណ្តឹងសាទុក្ខ *Furundžija* កថាខណ្ឌ ១៩០។

[២៨] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀងធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោក ចៅក្រម និល ណុន ចៅក្រម Sivia Cartwright ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne ចៅក្រម ធូ មុណី E55/4 ចុះថ្ងៃទី ២៣ មីនា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ ដែលប្តឹងជំទាស់ចៅក្រម") កថាខណ្ឌ ១២។ សេចក្តីសម្រេចលើបណ្តឹងបន្ទាន់របស់ សហមេធាវី ដែលប្តឹងជំទាស់ចំពោះចៅក្រម ន័យ ធុល ដោយត្រូវរង់ចាំបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីរបស់ នួន ជា C11/29 ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច ន័យ ធុល") កថាខណ្ឌ ១៥-១៧ (ដោយបានដកស្រង់ចេញពីសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ១៩៦)។

[២៩] សេចក្តីសម្រេច ន័យ ធុល កថាខណ្ឌ ១៥។ *សូមមើលផងដែរ* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ១៩៧ (ដោយបានកត់សម្គាល់ថា ចៅក្រមអាជីពមានសមត្ថភាពក្នុងការ "កែសេចក្តីយល់ខុសអំពីគំនិតរបស់ខ្លួនកុំឱ្យពាក់ព័ន្ធនឹងជំនឿផ្ទាល់ខ្លួន ឬការសម្រេចទុកជាមុនរបស់គាត់")។

ថាមានភាពលម្អៀង" ពីសំណាក់ជនជាប់ចោទណាមួយរូប គឺមិនគ្រប់គ្រាន់នោះទេ[៣០]។ ភាគីប្តឹងជំទាស់ដិតចិត្តត្រូវតែបង្ហាញរាល់ភស្តុតាងដែលខ្លួនយកមកធ្វើជាសំអាង នៅពេលខ្លួនដាក់ពាក្យប្តឹងជំទាស់ដិតចិត្ត[៣១]។ វិធាន ៣៥ នៃវិធានផ្ទៃក្នុងមិនមែនជាយន្តការសុក្រិត្យដើម្បីបង្ហាញនូវភស្តុតាងក្នុងការគាំទ្រលើបណ្តឹងជំទាស់ដិតចិត្តនេះឡើយ[32]។

១៥. លក្ខខណ្ឌជាមូលដ្ឋាន នៃបណ្តឹងជំទាស់ដិតចិត្តត្រូវបង្ហាញយ៉ាងហោចណាស់ក៏ត្រឹមមូលដ្ឋាននៃភស្តុតាងបឋម ដែលបញ្ជាក់ថា "ប្រសិនបើមានភាពលម្អៀងពិតប្រាកដមែន ឬភាពលម្អៀងដែលចៅក្រមប្រព្រឹត្តឱ្យឃើញច្បាស់ អាចនាំឱ្យប៉ះពាល់ដល់ភាពជឿទុកចិត្តក្នុងកិច្ចការរដ្ឋបាលតុលាការ ការប្តឹងជំទាស់ដិតចិត្តចៅក្រមទាំងនោះ ដោយផ្អែកលើការចោទប្រកាន់អំពីភាពលម្អៀងដែលគ្មានមូលដ្ឋានក៏អាចធ្វើឱ្យប៉ះពាល់ភាពជឿទុកចិត្តក្នុងរដ្ឋបាលតុលាការផងដែរ"[៣៣]។ លទ្ធផលនៃបណ្តឹងជំទាស់ដិតចិត្តដដែលៗ ឬឥតបានការ ដែលគេបានដាក់នៅចំពោះមុខសាលាក្តីអន្តរជាតិ គឺអាចនាំឱ្យមានការដាក់ទណ្ឌកម្ម ឬការព្រមានដាក់ទណ្ឌកម្មចំពោះអ្នកប្តឹង[៣៤]។

---

[៣០] *ព្រះរាជអាជ្ញា ទល់នឹង Karemera et al.*។ រឿងក្តីលេខ ICTR-98-44-T សេចក្តីសម្រេចលើបណ្តឹងរបស់ Joseph Nzirorera ដែលប្តឹងជំទាស់ដិតចិត្តចំពោះចៅក្រម Byron និងការផ្អាកកិច្ចដំណើរការនីតិវិធី ("បណ្តឹងជំទាស់ដិតចិត្តរបស់ Nzirorera") ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៥ (*សូមមើលផងដែរ* សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ១៩៧)។

[៣១] សេចក្តីសម្រេចលើបណ្តឹងរបស់ នួន ជា ដែលប្តឹងជំទាស់ដិតចិត្តចំពោះចៅក្រម Marcel Lemonde ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ១៨ (ឯកសារសាធារណៈដែលមានកោសលុប)។

[៣២] សេចក្តីសម្រេចស្តីពីការអនុវត្តវិធាន ៣៥ របស់ អៀង សារី លើបណ្តឹងជំទាស់ដិតចិត្តចៅក្រម Marcel Lemonde ថ្ងៃទី ២៩ ខែ មីនា ២០១០។ កថាខណ្ឌ ១១-១៤។

[៣៣] បណ្តឹងជំទាស់ដិតចិត្តរបស់ Nzirorera កថាខណ្ឌ ៦។ *សូមមើលផងដែរ* ព្រះរាជអាជ្ញា ទល់នឹង *Delalić et al* សំណុំរឿងលេខ IT-96-21-A សាលក្រម ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៧០៧ ("ទោះបីវាជាការសំខាន់ដែលថា យុត្តិធម៌ត្រូវតែមានក៏ដោយ ក៏វាមានសារៈសំខាន់ដូចគ្នាក្នុងការបង្ហាញឱ្យឃើញថា មន្ត្រីតុលាការត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងការជំនុំជម្រះក្តី និងអាចត្រូវលុះក្នុងសំណើដែលទំនងជាមានភាពលម្អៀងណាមួយ មិនត្រូវជំរុញភាគីឱ្យជឿថា តាមរយៈការប្តឹងជំទាស់ដិតចិត្តចៅក្រមណាមួយរូប ខ្លួននឹងបានចៅក្រមណាថ្មីមួយរូប ដើម្បីកាន់រឿងក្តីរបស់ខ្លួន ដែលទំនងជាអាចសម្រេចដើម្បីបានជាប្រយោជន៍ដល់ខ្លួននោះទេ")។

[៣៤] *សូមមើលឧទាហរណ៍ ព្រះរាជអាជ្ញា ទល់នឹង Blagojevic el. Al*។ សេចក្តីសម្រេចលើបណ្តឹង Blagojević សុំសេចក្តីបញ្ជាក់ ការិយាល័យរបស់សាលាក្តី ICTY Bureau (សំណុំរឿងលេខ IT-02-60-PT) ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ១ (ដោយគូសបញ្ជាក់ថា ការិយាល័យ "ពិចារណាយ៉ាងយកចិត្តទុកដាក់បំផុត" ចំពោះការដាក់ទណ្ឌកម្ម ដោយ

១៦. យុត្តិសាស្ត្រអន្តរជាតិ បានគូសបញ្ជាក់អំពីបទដ្ឋានដែលអនុវត្តសម្រាប់ការដាក់ឯកសាររបស់ភាគីតែម្ខាងពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធី[៣៥]។ ផ្ទុយទៅវិញ នៅពេលដែលការទាក់ទងគ្នារវាងរដ្ឋអាជ្ញាម្នាក់ និងចៅក្រមម្នាក់ មិនពាក់ព័ន្ធគ្នាទៅនឹងខ្លឹមសារសំខាន់ៗនៃកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តីណាមួយនោះ ការទាក់ទងគ្នាបែបនេះ គឺត្រូវបានសន្មតថាមិនបង្ហាញឱ្យឃើញភាពលម្អៀង ឬការស្តែងឱ្យឃើញអំពីភាពលម្អៀងនោះឡើយ[៣៦]។

a. ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីភាពលម្អៀង ដោយសារតែចៅក្រមនៃសាលាក្តី ICTY មួយរូប បដិសេធមិនឆ្លើយតបទៅនឹងសំណើសុំបង្ហាញការទំនាក់ទំនងទាំងអស់ របស់ចៅក្រមរូបនោះ ជាមួយនឹងទីប្រឹក្សាផ្នែកកិច្ចការស៊ីវិលរបស់អង្គការសហប្រជាជាតិ ប្រធានសាលាក្តី ICTY បានគូសបញ្ជាក់ថា "អង្គជំនុំជម្រះសាលាដំបូង ពីដំបូងបានបដិសេធសំណើសុំការបញ្ជាក់បន្ថែមស្តីពីលក្ខណៈនៃទំនាក់ទំនងរបស់ចៅក្រម Prandler ជាមួយនឹង Andreev រួចមកហើយ ដោយផ្អែកលើមូលដ្ឋាន ដែលថាចំណាត់ការដែលសមស្របជាងនេះមួយ គឺតម្រូវឱ្យមេធាវីការពារក្តីដាក់បណ្តឹងជំទាស់ ដោយអនុលោមតាមវិធាន ១៥(ខ) នៃវិធាន ដើម្បីអនុញ្ញាតឱ្យបញ្ហានេះត្រូវបានដោះស្រាយតាមរយៈ

---

អនុលោមតាមវិធាន ៤៦(គ) នៃវិធានរបស់សាលាក្តី ICTY ជាការឆ្លើយតបទៅនឹងបណ្តឹងដែលដាក់ដោយលោក Karnavas ស្នើសុំ "ការបញ្ជាក់" អំពីសេចក្តីសម្រេចពីពេលមុន ដែលបានបដិសេធបណ្តឹងជំទាស់ ដែលតុលាការបានសម្រេចរួចហើយថាជាបណ្តឹងដែលមានភាពដដែលៗដូចបណ្តឹងលើកមុនៗ)។

[៣៥] *ព្រះរាជអាជ្ញា ទល់នឹង Karemera et al.*។ សេចក្តីសម្រេចលើបណ្តឹងរបស់ Joseph Nzirorera ដែលស្នើសុំឱ្យបង្ហាញសារណាដែលដាក់ដោយភាគីតែម្ខាង ដើម្បីបង្ហាញឯកសារដែលមិនព្រមផ្តល់ឱ្យ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR (សំណុំរឿងលេខ ICTR-98-44-T) ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ៥ (ដោយកត់សម្គាល់ថា "ជាវិធានទូទៅ បណ្តឹងត្រូវតែដាក់ដោយអន្តរភាគី [...] ទោះជាយ៉ាងនេះក្តី បណ្តឹងរបស់ភាគីតែម្ខាងអាចជាការចាំបាច់ នៅពេលបណ្តឹងនោះឆ្លើយតបទៅនឹងប្រយោជន៍នៃយុត្តិធម៌ និងនៅពេលដែលការបង្ហាញទៅដល់ភាគីម្ខាងទៀតឱ្យបានដឹងអំពីព័ត៌មានដែលមានក្នុងបណ្តឹងនោះ អាចទំនងជាប៉ះពាល់ដល់បុគ្គលដែលពាក់ព័ន្ធទៅនឹងបណ្តឹង")។ *ព្រះរាជអាជ្ញា ទល់នឹង Karemera et al.*។ សេចក្តីសម្រេចលើបណ្តឹងរបស់ Joseph Nzirorera ដែលប្តឹងជំទាស់ចៅក្រម Byron ចៅក្រម Kam និងចៅក្រម Joensen ការិយាល័យ ICTR Bureau (សំណុំរឿងលេខ 98-44-T) ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៨។

[៣៦] *ព្រះរាជអាជ្ញា ទល់នឹង Karemera et al.*។ សេចក្តីសម្រេចលើបណ្តឹងរបស់ Joseph Nzirorera ដែលស្នើសុំឱ្យបង្ហាញលិខិតផ្តល់អនុសាសន៍ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR (សំណុំរឿងលេខ ICTR-98-44-T) ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៦ ("ការវាយតម្លៃរបស់ចៅក្រមប្រធានអំពីអ្នកដាក់បណ្តឹងរបស់ក្រុមមេធាវី Queen's Counsel មិនបានបង្ហាញអំពីភាពលម្អៀង ឬការបង្ហាញឱ្យឃើញអំពីភាពលម្អៀង")។

យន្តការដែលមានចែងក្នុងវិធាន"[៣៧]។ បណ្តឹងបន្ទាប់នោះ ត្រូវបានបដិសេធដោយសំអាងលើមូលហេតុ ដែលថា មេធាវីការពារក្តី "មិនបានផ្តល់ភ័ស្តុតាងដើម្បីគាំទ្រដល់បណ្តឹងរបស់ខ្លួន ហេតុដូច្នេះ តុលាការមិនចាំបាច់ចាត់តាំងគណៈកម្មាធិការមួយដើម្បីដោះស្រាយបណ្តឹងនោះទេ"[៣៨]។

១៨. ទោះបីជាមានការសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃឯករាជ្យភាព និងភាពអនាគតិ យ៉ាងណាក៏ដោយ ក៏ក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក ពុំមានចែងអំពីបទប្បញ្ញត្តិជាក់លាក់ណាមួយស្តីពីការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* ឡើយ[39]។ ក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក គឺសម្រាប់អនុវត្តចំពោះចៅក្រមអន្តរជាតិនៃ អ.វ.ត.ក ហើយក្រមសីលធម៌របស់តុលាការជាតិមិនអនុវត្តចំពោះចៅក្រមអន្តរជាតិនៃ អ.វ.ត.ក ទេ"[40]។

## ៥. សំអាងហេតុ

១៩. ទោះបីជាមានការយល់ស្របជាមួយសហព្រះរាជអាជ្ញាថា សំណើរបស់មេធាវីការពារក្តី ពុំបានបំពេញនូវកម្រិតនៃលក្ខខណ្ឌតម្រូវស្តីពីភ័ស្តុតាង ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៣៤ ក៏ដោយ ក៏សំណើទាំងនេះត្រូវបដិសេធបន្ថែមទៀតថាពុំមានមូលដ្ឋានគ្រប់គ្រាន់។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា នៅចំពោះមុខតុលាការអន្តរជាតិ និងតុលាការដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម ការជួបប្រាស្រ័យរវាងប្រធានអង្គជំនុំជម្រះ រដ្ឋអាជ្ញា និងប្រធានការិយាល័យរដ្ឋបាល គឺជារឿងធម្មតា[41]។ ក្រុមប្រឹក្សាសម្របសម្រួលទាំងនេះធានានូវកិច្ចសម្របសម្រួល

[៣៧] *ព្រះរាជអាជ្ញា ទល់នឹង Prlić et. al.*។ សេចក្តីសម្រេចរបស់ចៅក្រមប្រធានស្តីពីពាក្យបណ្តឹងរបស់ Jadranko Prlić ដែលប្តឹងជំទាស់ចៅក្រម Árpád Prandler ប្រធានសាលាក្តី ICTY (សំណុំរឿងលេខ IT-04-74-T) ("សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ Prlić") ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០១០ កថាខណ្ឌ ១៤។

[៣៨] សេចក្តីសម្រេចលើបណ្តឹងជំទាស់របស់ Prlić កថាខណ្ឌ ៣០។

[39] ក្រមសីលធម៌តុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា ១ និង ២។

[40] ក្រមសីលធម៌តុលាការរបស់ អ.វ.ត.ក (ដោយពិចារណាលើចរិតលក្ខណៈចំរុះគ្នានៃ អ.វ.ត.ក និងភាពចាំបាច់ក្នុងការអនុម័តក្រមសីលធម៌សម្រាប់អនុវត្តចំពោះចៅក្រមជាតិ និងអន្តរជាតិ ដោយរួមបញ្ចូលនូវបទដ្ឋានជាតិ និងអន្តរជាតិ)។

[41] វិធាន ២៣*ស្ទួន* វិធាននៃនីតិវិធី និងភ័ស្តុតាង របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (ដែលក្រុមប្រឹក្សាសម្របសម្រួលរបស់តុលាការទាំងនេះ រួមមាន "ប្រធាន រដ្ឋអាជ្ញា និងប្រធានរដ្ឋបាល" និង "ត្រូវជួបប្រជុំមួយម្តងក្នុងមួយខែ")។ បញ្ញត្តិ ៣ នៃបទប្បញ្ញត្តិរបស់តុលាការ ICC (ដែលក្រុមប្រឹក្សាសម្របសម្រួលរបស់តុលាការនេះរួមមាន "ប្រធាន ក្នុងនាមជាប្រធាន រដ្ឋអាជ្ញា និងប្រធានរដ្ឋបាល")។

និងប្រតិបត្តិការ នៃសកម្មភាពរដ្ឋបាលប្រកបដោយប្រសិទ្ធភាព រវាងផ្នែកទាំងបីរបស់តុលាការទាំងនេះ និងមានលក្ខណៈចាំបាច់ និងមានសារៈសំខាន់ក្នុងការដោះស្រាយចំពោះការជំទាស់តវ៉ាពិសេសផ្នែករដ្ឋបាល ដែលតុលាការអន្តរជាតិទាំងនេះប្រឈម[42]។ នៅក្នុងតុលាការនីមួយៗក្នុងចំណោមតុលាការទាំងនេះ មេធាវីការពារក្តីពុំមានតួនាទីនៅក្នុងក្រុមប្រឹក្សាសម្របសម្រួលឡើយ។ ប្រសិនបើមានការរៀបចំកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាសម្របសម្រួល កំណត់ហេតុនោះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ។

២០. ផ្ទុយទៅនឹងការអះអាងរបស់ពួកគាត់ សំណើរបស់ នួន ជា និង អៀង សារី សុំព័ត៌មានស្តីពីកិច្ចប្រជុំទាំងនេះ ត្រូវបានឆ្លើយតបយ៉ាងគ្រប់គ្រាន់តាមរយៈអ៊ីមែលរបស់អនុប្រធានរដ្ឋបាលថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។ អ៊ីមែលនេះ បានបញ្ជាក់ច្បាស់ថា បន្ទាប់ពីមានការផ្តល់យោបល់ពីទីប្រឹក្សាផ្នែកច្បាប់របស់អង្គការសហប្រជាជាតិ កិច្ចប្រជុំរវាងចៅក្រម Cartwright សហព្រះ-រាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល ត្រូវបានយកគំរូក្រៅផ្លូវការតាមតុលាការ ICTR តុលាការ ICTY និងតុលាការ ICC ដែលកិច្ចប្រជុំនេះ ត្រូវបានកែសម្រួលឱ្យស្របទៅនឹងបរិបទជាក់លាក់របស់ អ.វ.ត.ក។ អ.វ.ត.ក មិនមានប្រធានដូចតុលាការទាំងនោះទេ។ ចៅក្រមកម្ពុជា ជាប្រធានអង្គជំនុំជម្រះនានានៃអ.វ.ត.ក ខណៈដែលអ.វ.ត.ក មានបញ្ហាប្រឈមខាងផ្នែករដ្ឋបាលដែលទាក់ទងតែចំពោះសមាសភាពអង្គការសហប្រជាជាតិនៃតុលាការនេះនោះ ហេតុដូច្នេះចៅក្រម Cartwright ដែលជាអនុប្រធាននៃកិច្ចប្រជុំពេញអង្គអាចចូលរួមប្រជុំនេះបាន។ ទោះបីជាតុលាការនេះកើតចេញពីលក្ខណៈជាកូនកាត់ និងមាន ទំហំតូច ដែល អ.វ.ត.ក ពុំមានរចនាសម្ព័ន្ធផ្លូវការទាំងអស់ ដែលមាននៅក្នុងតុលាការ *មិនអចិន្ត្រៃយ៍* និងតុលាការ ICC ក៏ដោយក៏អនុប្រធានរដ្ឋបាលមានតួនាទីស្រដៀងគ្នា ទៅនឹងតួនាទីរបស់ប្រធាន រដ្ឋបាលនៅតុលាការអន្តរជាតិផ្សេងៗទៀត។ ដូច្នេះ ប្រធានទាំងអស់មានការទទួលខុសត្រូវដែលមិន ពាក់ព័ន្ធនឹងតុលាការ និងការទទួលខុសត្រូវផ្នែករដ្ឋបាលដ៏សំខាន់ ដែលមានវិសាលភាពដូចជា ការគ្រប់គ្រងការផ្តល់យោបល់ ថវិកា ការចាត់ចែងបុគ្គលិក និង ទំនាក់ទំនងកម្រិតខ្ពស់ជាមួយ មន្ត្រីជាន់ខ្ពស់អង្គការសហប្រជាជាតិ អ្នកការទូត បុគ្គលសំខាន់ៗ និងម្ចាស់ជំនួយ។ តួនាទីទាំងនេះ សំខាន់ណាស់ដើម្បីធានាថាសមាសភាពអន្តរជាតិរបស់ អ.វ.ត.ក មានធនធានចាំបាច់ និងការគាំទ្រផ្នែក ភស្តុភារ និងផ្នែករដ្ឋបាល ដើម្បីបំពេញអាណត្តិរបស់ខ្លួន។ ដូចដែលបានបញ្ជាក់ យ៉ាងច្បាស់តាមរយៈ

---

[42] វិធាន ២៣ស្ទួន (ខ) របស់តុលាការ ICTR។ វិធាន ២៣ស្ទួន (ខ) របស់តុលាការ ICTY។ បញ្ញត្តិ ៣(២) របស់តុលាការ ICC។

អ៊ីមែលនេះ បញ្ហាដែលយកមកពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនេះ ពាក់ព័ន្ធ នឹងបញ្ហាប្រតិបត្តិដែលប៉ះពាល់ដល់សមាសភាពអន្តរជាតិរបស់ អ.វ.ត.ក និងមិនពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីរបស់ អ.វ.ត.ក ឡើយ ហើយប្រាកដណាស់មិនពាក់ព័ន្ធនឹងជនជាប់ចោទណា ម្នាក់ឡើយនៅចំពោះមុខនេះឡើយ។

២១. ទោះបីជាការជួបប្រជុំរវាងអនុប្រធាននៃកិច្ចប្រជុំពេញអង្គ សហព្រះរាជអាជ្ញា និងអនុប្រធានរដ្ឋបាល មិនត្រូវបានពិពណ៌នាឲ្យបានច្បាស់នៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ក៏ដោយ ក៏ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក មិនបានហាមឃាត់មិនឲ្យមានការសម្របសម្រួលដោយសមាសភាពអង្គការសហប្រជាជាតិ របស់ អ.វ.ត.ក ឡើយ ក្នុងករណីចាំបាច់។ គណៈកម្មាធិការរដ្ឋបាលតុលាការ ដែលបង្កើតឡើង ដោយវិធានផ្ទៃក្នុង ១៩ រួមមានទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ (ចៅក្រមខ្លះមិនស្នាក់នៅក្នុង ប្រទេសកម្ពុជាទេ) និងមិនត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាដែលទាក់ទិនតែទៅនឹងសមាសភាពអង្គការសហប្រជាជាតិរបស់ អ.វ.ត.ក ប៉ុណ្ណោះឡើយ។ ហើយគណៈកម្មាធិការនេះក៏មិនមានសមត្ថកិច្ចផ្ដាច់មុខ ទាក់ទិននឹងការគ្រប់គ្រង និងការសម្របសម្រួលផ្នែករដ្ឋបាលដែរ។

២២. ដោយសារតែមូលដ្ឋានចំពោះបណ្ដឹងជំទាស់ចៅក្រម មិនអាចបង្កើតឡើងតាមរយៈការចោទប្រកាន់អំពីការប្រព្រឹត្តិខុសឆ្គងដែលពុំមានភស្តុតាងបង្ហាញនោះ អត្ថិភាពតែមួយគត់នៃការជួបប្រជុំក្រៅផ្លូវការ រវាងអនុប្រធាននៃកិច្ចប្រជុំពេញអង្គ សហព្រះរាជអាជ្ញា និងអនុប្រធានរដ្ឋបាល ពុំអាចបដិសេធ សច្ចធារណ៍ដែលថាចៅក្រម Cartwright មិនលម្អៀង និងអនាគតិ នៅក្នុងការអនុវត្តតួនាទីចៅក្រម របស់លោកស្រីបានឡើយ។ ដូច្នេះ អង្គជំនុំជម្រះពិចារណាថា ការចូលរួមរបស់ចៅក្រម Cartwright នៅក្នុងកិច្ចប្រជុំទាំងនេះ នឹងមិនបង្កើតបានជាការព្រួយបារម្ភសមហេតុផលអំពីភាពលម្អៀងពីសំណាក់បុគ្គលម្នាក់ ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ និងយល់ដឹងអំពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ឡើយ។ ជាពិសេស ការជួបប្រជុំនេះ គឺមិនបានពាក់ព័ន្ធទៅនឹងបញ្ហាទាំងឡាយនៃរឿងក្ដីដែលមាននៅចំពោះមុខ អ.វ.ត.ក ឡើយ។

**យោងទៅលើហេតុផលដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូង ៖**

**បដិសេធ** សំណើរបស់ អៀង សារី សុំឲ្យមានការស៊ើបអង្កេត។

**បដិសេធ** សំណើរបស់មេធាវីការពារក្ដី អៀង សារី សុំឲ្យកោះហៅសហព្រះរាជអាជ្ញាអន្តរជាតិ។

**បដិសេធ** បណ្តឹងជំទាស់ដោយសង្ស័យលើភាពមិនលំអៀងរបស់ នួន ជា ចំពោះចៅក្រម Cartwright និង

**បដិសេធ** សំណើរបស់ អៀង សារី សុំឱ្យមានសវនាការជាសាធារណៈលើបញ្ហានេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE
E.C.C.C. C.E.T.C.

**និល ណុន**